00642982

E9/6

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសប

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ៨ កុម្ភៈ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ស.ប៖ **សាធារណៈ / Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើសុំពន្យារពេលដាក់ឯកសារភស្តុតាង

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក ស សូវ៉ាន

លោក Jacques VERGES

លោក Philippe GRECIANO

**ផ្ញើជូន៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម Silvia CARTWRIGHT

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 08 / 02 / 2011
ម៉ោង (Time/Heure) : 14:55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

00642983



# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានបញ្ជូនលោក ខៀវ សំផន ទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1]។

២. កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថេរៈវេលាសម្រាប់ឲ្យភាគីដាក់សំណុំឯកសារភ័ស្តុតាងនានា ដោយអនុវត្តតាមជាអាទិ៍វិធាន ៨០ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ("វិធានផ្ទៃក្នុង")។ មេធាវីការពារ និងភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតម្រូវឲ្យដាក់នូវបញ្ជីឈ្មោះសាក្សីបន្ថែមរបស់ខ្លួនក្នុងថេរវេលា១៥ថ្ងៃ គិតចាប់តាំងពីពេលដែលមានការជូនដំណឹង អំពីបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញា។ រាល់ភាគីទាំងឡាយត្រូវដាក់បទសង្ខេបមួយ ស្តីអង្គហេតុនានាពាក់ព័ន្ធទៅនឹងសក្ខីកម្មនីមួយៗដែលបានស្នើឡើង យ៉ាងយូរត្រឹមថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ព្រមទាំងដាក់បញ្ជីឈ្មោះឯកសារនិងភ័ស្តុតាងនានា ឲ្យបានយ៉ាងយូរត្រឹមថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១១ ដោយមានការពិពណ៌នាសង្ខេបអំពីប្រភេទ និងខ្លឹមសារនៃឯកសារទាំងនោះ[2]។

៣. កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ មេធាវីការពារបានទទួលនូវសេចក្តីជូនដំណឹងជាភាសាអង់គ្លេស និងជាភាសាខ្មែរ អំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលសហព្រះរាជអាជ្ញាមានបំណងចង់ឲ្យពួកគេចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ ដែលក្នុងនោះមានចំនួនឈ្មោះសរុប ២៩៤ នាក់[3]។ យោងទៅលើបទបញ្ញត្តិ នៃសេចក្តីណែនាំអនុវត្តពាក់ព័ន្ធនឹងការដាក់ឯកសារទៅ អ.វ.ត.ក. និងទៅលើការអនុវត្តជាធរមាន ថេរៈវេលា១៥ ថ្ងៃ ដែលផ្តល់ជូនលោក ខៀវ សំផន ដែលលោកបានជ្រើសរើស

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ D427/4/14។

[2] ដីកាបង្គាប់ឲ្យភាគីដាក់ឯកសារភ័ស្តុតាងដើម្បីត្រៀមរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ឯកសារ E9 (" ដីកាបង្គាប់ ")។

[3] បញ្ជីឈ្មោះអ្នកជំនាញរបស់ ក.ស.ព ឯកសារ E9/4.2, មានឈ្មោះ ១៦នាក់, បញ្ជីឈ្មោះសាក្សីរបស់ ក.ស.ព ឯកសារ E9/4.3, មានឈ្មោះ ២៤៦នាក់, បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីរបស់ ក.ស.ព ឯកសារ E9/4.4, មានឈ្មោះ ៣២នាក់។

យកភាសាបារាំងជាភាសាផ្លូវការនោះ នឹងចាប់ផ្ដើមគិតបន្ទាប់ពីមានការជូនដំណឹងជាភាសាបារាំងអំពីបញ្ជីឈ្មោះរបស់សហព្រះរាជអាជ្ញាប៉ុណ្ណោះ[4]។

៤. លោក ខៀវ សំផន ស្នើសុំឲ្យមានការពន្យារថេរវេលាដែលបានដាក់កម្រិតមកលើគាត់តាមរយៈដីកា ហើយថេរវេលានេះនឹងត្រូវបានរាប់ចាប់ពីពេលដែលមានការជូនដំណឹងជាភាសាបារាំងពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងសំណើសុំនេះ។[5]

៥. ជាក់ស្ដែង លោក ខៀវ សំផន លើកឡើងថាថេរៈវេលាកំណត់បានរំលោភលើសិទ្ធិជាសារវន្តបំផុតរបស់លោក។ គាត់បានរំលឹកថា រូបគាត់ត្រូវបានសន្មត់ជាមុនថាគ្មានទោស រហូតដល់ពេលដែលពិរុទ្ធភាពរបស់គាត់ត្រូវបានរកឃើញ នៅក្នុងដំណាក់ចុងក្រោយនៃនីតិវិធី ហើយមានតែអយ្យការទេដែលមានកាតព្វកិច្ចបង្ហាញអំពីពិរុទ្ធភាពរបស់គាត់ ហើយជាទីបញ្ចប់ តុលាការត្រូវតែធានាសិទ្ធិរបស់គាត់ក្នុងការទទួលបាននូវការកាត់សេចក្ដី ដោយយុត្តិធម៌ និងដោយឆាប់រហ័ស។

## ១. ការរំលោភលើគោលការណ៍សច្ចធារណ៍និរទោស និងបន្ទុកនៃភស្តុតាង

៦. នីតិអន្តរជាតិនៃសិទ្ធិមនុស្ស និងនីតិព្រហ្មទណ្ឌអន្តរជាតិបានទទួលស្គាល់ថា រាល់ជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ត្រូវបានសន្មត់ថាគ្មានទោសរហូតដល់ពេលដែលពិរុទ្ធភាពរបស់ជននោះត្រូវបានរកឃើញដោយស្របច្បាប់ និងជាស្ថាពរ[6] ដោយគោរពដល់គោលការណ៍ទូទៅនៃច្បាប់ដែលតម្រូវឲ្យអយ្យការជាអ្នកបង្ហាញ

---

[4] មាត្រា ២.២ និង៨.៥ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅអ.វ.ត.កឯកសារអ.វ.ត.ក/០១/២០០៧/ វ០៥។

[5] វិធាន ៣៩ ៤) ក)៖ "តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាច៖ក-ពន្យាពេលវេលាកំណត់ ដែលខ្លួនបានសម្រេច"។

[6] មាត្រា ១១ ១) នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ("DUDH"), មាត្រា ១៤ ២) នៃ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("PIDCP"), មាត្រា ៦ ២) នៃអនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិសេរីភាពជាមូលដ្ឋាន ("CESDH"), មាត្រា ២០ ៣) នៃ លក្ខន្តិកតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ ប្រទេសរវ៉ាន់ដា ("TPIR"), មាត្រា ២១ ៣) នៃ លក្ខន្តិកតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("TPIY"), មាត្រា ៦៦ ១) នៃលក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ ("CPI"), មាត្រា ១៦ ៣) ក) នៃ លក្ខន្តិកៈ តុលាការពិសេសសម្រាប់ប្រទេសលីបង់ ("TSL")។

ពិរុទ្ធភាពរបស់ជនជាប់ចោទ។[7]

៧. យោងទៅលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងការចោទប្រកាន់ ស្របតាមច្បាប់របស់កម្ពុជា លើជនល្មើសនៃឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានប្រព្រឹត្តក្នុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងវិធានផ្ទៃក្នុង គោលការណ៍សច្ចធារណ៍និរទោសត្រូវអនុវត្តនៅចំពោះមុខ អ.វ.ត.ក.។[8]

៨. យោងលើវិធាន ២១ ១) ក) នៃវិធានផ្ទៃក្នុង "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ" [9]។ ម្យ៉ាងទៀត វិធាន៨៧ ១) បានចែងយ៉ាងច្បាស់ថា "សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ"។

---

[7] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា រឿងក្តី *Zigiranyirazo* *តទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-01-73-A សាលដីកា ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ៣៨ កំណត់សម្គាល់ជើងទំព័រ១០៥; តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Ntagerura និងអ្នកផ្សេងទៀត*, សំណុំរឿងលេខ ICTR-99-46-A សាលដីកា ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ១៧០; តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា រឿងក្តី *Rutaganda* *តទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-96-3-A សាលដីកា ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ១៧២; តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីត ប្រទេសយូហ្គោស្លាវី រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kordic et Cerkez*, សំណុំរឿងលេខ IT-95-14/2-A សាលដីកា ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ៨៣៥។

[8] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ១៣ ១) នៃកិច្ចព្រមព្រៀង, មាត្រា ៣៥ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, វិធាន ២១ ១) ឃ) នៃវិធានផ្ទៃក្នុង។

[9] ដោយផ្អែកតាមវិធាននេះ អង្គបុរេជំនុំជម្រះ នៃអ.វ.ត.ក បានពិចារណាពីការវិវត្តនៃប្រព័ន្ធដែលផ្តល់អំណាចលើសលុបដល់ចៅក្រម "ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការពិចារណា អំពីសិទ្ធិរបស់ជនជាប់ចោទនៅ **គ្រប់ដំណាក់កាលនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ**"៖ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងដីកាសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2/4 កថាខណ្ឌ១៧។

៩. វិធាន៨០ នៃវិធានផ្ទៃក្នុងបានចែងផ្ទុយអំពីបទបញ្ញត្តិទាំងនេះ។ លោក ខៀវ សំផន ត្រូវបានសន្មត់ថាគ្មានទោស ដរាបណាអយ្យការបានបង្ហាញនូវភ័ស្តុតាងផ្ទុយ ពោលគឺលោក ខៀវ សំផន អាចដាក់នូវឯកសារភ័ស្តុតាងនានាដើម្បីធ្វើការការពារខ្លួនលោកបាន បន្ទាប់ពីមានការបង្ហាញនូវធាតុផ្សំភ័ស្តុតាងដាក់បន្ទុក**ទាំងអស់**រួចមក។

១០. ដោយគោរពតាមគោលការណ៍ជាសារវន្តទាំងនេះហើយទើប នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ មេធាវីការពារនឹងដាក់ឯកសារភ័ស្តុតាង បន្ទាប់ពីមានការបង្ហាញអំពីមធ្យោបាយនៃភ័ស្តុតាងដាក់បន្ទុកប៉ុណ្ណោះ ឬអាចនិយាយបានម្យ៉ាងទៀតថា បន្ទាប់ពីពេលដែលសាក្សីដាក់បន្ទុកបានចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការ។ [10]

១១. នៅក្នុងចំណោមតុលាការអន្តរជាតិនានា ប្រព័ន្ធតុលាការដែលមានលក្ខណៈស្រដៀងគ្នាបំផុតទៅនឹងប្រព័ន្ធដែលអនុវត្តនៅ អ.វ.ត.ក. គឺប្រព័ន្ធតុលាការសារ៉ាឡេអូន ជាពិសេសដោយសារតែតួនាទីសកម្មរបស់ជនរងគ្រោះ[11] ក៏ដូចជាវត្តមាននៃចៅក្រមត្រួតពិនិត្យ

---

[10] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី៖ មាត្រា ៦៥ *ស្ទួនពីរ* ឆ នៃវិធាននីតិវិធី និងភ័ស្តុតាង(“RPP”); តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា៖ មាត្រា ៧៣ *ស្ទួនពីរ* ខ នៃវិធាននីតិវិធី និងភ័ស្តុតាង ; តុលាការពិសេសសម្រាប់ប្រទេសលីបង់៖ មាត្រា ១២៨ នៃវិធាននីតិវិធី និងភ័ស្តុតាង។

[11] ជាថ្មីម្តងទៀត ការដែលជនរងគ្រោះចូលរួមនៅក្នុងនីតិវិធីរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ អាចមានតួនាទីសកម្មជាងនេះនោះ គឺដោយសារតែជនរងគ្រោះទាំងនោះមិនមានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី និងមិនអាចសុំសំណងបាន។ សូមមើលសារណាពន្យល់វិធាននីតិវិធី និងភ័ស្តុតាង រៀបរៀងដោយប្រធានតុលាការ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ១៦-១៧។ ដូច្នេះ ការប្រុងប្រយ័ត្នខ្ពស់ចំពោះការគោរពសិទ្ធិមេធាវីការពារក្តី ត្រូវតែបានធានានៅចំពោះមុខអ.វ.ត.ក។ បញ្ហាសមភាពនៃគូភាគីក្នុងការការពារក្តី ប្រឈមនឹងដើមបណ្តឹងរដ្ឋប្បវេណី គឺជាបញ្ហា “អាចបង្កឲ្យប៉ះពាល់ដល់យុត្តិធម៌ផ្នែកនីតិវិធី” ដូចដែលត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តីរបស់ “ឌុច”។ អង្គជំនុំជម្រះយល់ឃើញថា “នៅក្នុងរឿងព្រហ្មទណ្ឌ សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ **គឺជាសិទ្ធិក្នុងការប្រឈមតែជាមួយនឹងភាគីចោទប្រកាន់តែមួយប៉ុណ្ណោះ**”។ សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅ ឲ្យផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ សំណុំរឿង ០០១ ឯកសារ E72/3 ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ២៦ (មិនបានគូសបន្ទាត់ពីក្រោម នៅក្នុងអត្ថបទដើម)។

និយ័តភាពនៃសំណុំរឿង ដែលទទួលបាននូវអំណាចដ៏សម្បើម ពេលខ្លះមានលក្ខណៈដូចគ្នាទៅនឹងអំណាចរបស់ចៅក្រមស៊ើបអង្កេតនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល (*Civil law*) ឬប្រព័ន្ធច្បាប់រ៉ូម៉ាណូហ្សែរម៉ានិកដែរ។ [12]

១២. នៅចំពោះមុខតុលាការនេះ ជនរងគ្រោះដាក់បញ្ជីឈ្មោះសាក្សីនានាដែលខ្លួនចង់ឱ្យមានការកោះហៅសាក្សីទាំងនោះឱ្យចូលខ្លួននៅចំពោះមុខតុលាការ នៅក្នុងដំណាក់កាលដូចគ្នាទៅនឹងសហព្រះរាជអាជ្ញាដែរ ដូចជានៅក្នុងដំណាក់កាលត្រៀមរៀបចំជំនុំជម្រះក្តី។[13] ចំណែកឯមេធាវីការពារវិញ ដាក់ឯកសារភស្តុតាងរបស់ខ្លួនក្នុងអំឡុងពេលជំនុំជម្រះ បន្ទាប់ពីមានការបង្ហាញនូវមធ្យោបាយភស្តុតាងដាក់បន្ទុក។[14]

១៣. នៅក្នុងរឿងក្តី *Lubanga* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានបង្គាប់ឱ្យជនត្រូវចោទដាក់ឯកសារភស្តុតាង "នៅពេលដែលអយ្យការបានបង្ហាញ នូវរាល់ឯកសារភស្តុតាងរបស់ខ្លួនរួចមក"។[15] នៅក្នុងការវិភាគរបស់ខ្លួន អង្គជំនុំជម្រះបានកំណត់នូវការប្រើប្រាស់អំណាចដ៏ត្រឹមត្រូវដែលអង្គជំនុំជម្រះមាន ពាក់ព័ន្ធទៅនឹងការដាក់ឯកសារពីសំណាក់មេធាវីការពារ៖ " វាជារឿងដែលសំខាន់បំផុត ក្នុងការអនុវត្តអំណាចទាំងនោះតែក្នុងករណីដែលអំណាចទាំងនោះមានលក្ខណៈសមហេតុផល ហើយអនុវត្តទៅលើអង្គហេតុ និងចំណុចទាំងឡាយដែលគេបានស្គាល់ ដោយគិតដល់អត្ថប្រយោជន៍នៃយុត្តិធម៌ និងកាលៈទេសៈនៃរឿងក្តី។ អង្គជំនុំជម្រះមាន **កាតព្វកិច្ចដាច់ខាត** ក្នុងការធានាជានិច្ចជាកាលថា ដីកាដែលពាក់ព័ន្ធទៅនឹងការដាក់ឯកសារមួយចំនួនពីសំណាក់មេធាវីការ

---

[12] សូមមើលជាពិសេស មាត្រា ៧ ក) និង ១៨ នៃលក្ខន្តិក និងមាត្រា ៩២ និង ៩៣ នៃវិធាននីតិវិធី និងភស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសលីបង់ ដែលតាមរយៈមាត្រាទាំងនោះ ចៅក្រមអង្គបុរេជំនុំជម្រះ ដែលមានឯករាជ្យនិងមានស្វ័យភាពពីអង្គជំនុំជម្រះសាលាដំបូង អាចប្រមូលភស្តុតាង ឬអាចសម្ភាសសាក្សីក្នុងកាលៈទេសៈមួយចំនួន។

[13] មាត្រា ៩១ ជ) នៃវិធាននីតិវិធី និងភស្តុតាង របស់តុលាការពិសេសសម្រាប់ប្រទេសលីបង់។

[14] មាត្រា ១២៨ i) នៃវិធាននីតិវិធី និងភស្តុតាង របស់តុលាការពិសេសសម្រាប់ប្រទេសលីបង់។

[15] តុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តី *ព្រះរាជអាជ្ញា តទល់នឹង* Thomas Lubanga Dyilo សំណុំរឿងលេខ ICC-01/04-01/06, សេចក្តីសម្រេចស្តីពីការផ្តល់ភស្តុតាងមួយចំនួនដោយក្រុមមេធាវីការពារក្តី ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ កថាខណ្ឌ៤១។

00642988



ពារ ដែលដីកានោះបានចេញក្នុងក្របខណ្ឌនៃអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន មិនបានរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ និងដោយអនាគតិ ដែលការពារនូវរាល់សិទ្ធិរបស់ជនជាប់ចោទនោះ"។[16]

១៤. អង្គជំនុំជម្រះបានសម្រេចថា សិទ្ធិទាំងឡាយរបស់មេធាវីការពារ "មិនអាចរំលោភបំពានបានឡើយ" ៖ "ជនជាប់ចោទត្រូវបានសន្មត់ជាមុនថាគ្មានទោស រហូតដល់ពេលដែលពិរុទ្ធភាពរបស់ខ្លួនត្រូវបានរកឃើញ (...) សហព្រះរាជអាជ្ញាជាអ្នកដែលត្រូវបង្ហាញពិរុទ្ធភាពរបស់ជនជាប់ចោទ (...) គាត់មិនត្រូវបានតម្រូវឱ្យបង្វែរបន្ទុកនៃភ័ស្តុតាង ក៏ដូចជាបន្ទុកនៃការឆ្លើយបដិសេធឡើយ (...) គាត់មិនអាចត្រូវបានបង្ខំឱ្យផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬក៏ទទួលស្គាល់ពិរុទ្ធភាពរបស់ខ្លួនឡើយ ព្រមទាំងមានសិទ្ធិនៅស្ងៀមមិននិយាយ ហើយសិទ្ធិនៅស្ងៀមនេះទៀតសោត មិនត្រូវបានគេយកមកពិចារណាដើម្បីកំណត់ពិរុទ្ធភាព ឬនិរទោសភាពរបស់ខ្លួននោះឡើយ"។[17]

១៥. ដោយសារភាពមិនអាចរំលោភបំពានបាននៃសិទ្ធិទាំងនេះ ដែលទទួលស្គាល់ដោយយុត្តិសាស្ត្រអន្តរជាតិ និងនៅចំពោះមុខ អ.វ.ត.ក.[18] ទើបលោក ខៀវ សំផន ត្រូវដាក់ឯកសារភ័ស្តុតាងដែលលោកមានបំណងនឹងបង្ហាញ បន្ទាប់ពីការបង្ហាញនូវឯកសារភ័ស្តុតាងទាំងមូលរបស់សហព្រះរាជអាជ្ញា និងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

---

[16] *យោងដូចដើងទំព័រខាងលើ* កថាខណ្ឌ៣២-៣៣។ នៅក្នុងរឿងក្តីដដែលនេះដែរ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ទើបនឹងបានរំឭក ពីបច្ចុប្បន្នភាពនៃទឡ្ហីករណ៍នេះ៖ *Redacted Second Decision on disclosure by the defence and Decision on whether the prosecution may contact defence witnesses*, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ កថាខណ្ឌ ៥៧។

[17] *យោងដូចដើងទំព័រខាងលើ* កថាខណ្ឌ២៧ (មិនបានគូសបន្ទាត់ពីក្រោមនៅក្នុងអត្ថបទដើម)។

[18] សូមមើល យោងខាងលើ កថាខណ្ឌ០៧ និង ០៨, មាត្រា ៣៥ (ថ្មី) ច) នៃច្បាប់បង្កើតអ.វ.ត.ក៖ "នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាម... មិនត្រូវបានគេបង្ខំឱ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឱ្យឆ្លើយសារភាពថាមានកំហុស"។

## ២. ការរំលោភលើសិទ្ធិក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌ និងឆាប់រហ័ស

### ក. កង្វះខាតនូវពេលវេលា និងភាពងាយស្រួលចាំបាច់នានាសម្រាប់ត្រៀមការពារខ្លួន

១៦. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងសន្ធិសញ្ញាអឺរ៉ុបស្តីពីការគាំពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ទទួលស្គាល់ថា រាល់បុគ្គលទាំងឡាយដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិ ដោយស្មើភាពគ្នា ក្នុងការទទួលបាននូវពេលវេលា និងភាពងាយស្រួលចាំបាច់នានាសម្រាប់ត្រៀមការពារខ្លួន នៅចំពោះមុខតុលាការ[19]។ វាជាការអនុវត្តជាក់ស្តែងនូវគោលការណ៍សមភាព នៃមធ្យោបាយការពារក្តី[20] ដែលជា "គោលការណ៍គ្រឹះដើម្បីធានានូវការកាត់សេចក្តីប្រកប ដោយយុត្តិធម៌"។[21]

១៧. គណៈកម្មាធិការសិទ្ធិមនុស្សបញ្ជាក់ថា "រយៈពេលចាំបាច់" ពឹងផ្អែកទៅលើករណីជាក់ស្តែង ហើយ "ភាពងាយស្រួលចាំបាច់" រួមមាន "ការទទួលបាននូវឯកសារ និងភស្តុតាងនានា ព្រមទាំងឯកសារភស្តុតាងដាក់បន្ទុកទាំងឡាយ ដែលអយ្យការមានបំណងនឹងបង្ហាញក្នុងអង្គសវនាការ ឬក៏ឯកសារភស្តុតាងដោះបន្ទុកទាំងឡាយ។"[22]

---

[19] មាត្រា ១៤ ៣) ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិ សេរីភាពជាមូលដ្ឋាន, មាត្រា ៣១ និង ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ១៣ ១) នៃកិច្ចព្រមព្រៀង, មាត្រា ៣៥ (ថ្មី) នៃច្បាប់បង្កើត អ.វ.ត.ក។

[20] គណៈកម្មាធិការសិទ្ធិមនុស្ស សំណុំរឿងលេខ ២៨២/១៩៨៨, រឿងក្តី Smith តទល់នឹង Jamaïque ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៣ កថាខណ្ឌ១០.៤; និងសំណុំរឿងលេខ ២២៦ និង ២៥៦/១៩៨៧ រឿងក្តី Sawyers, Mclean et Mclean តទល់នឹង Jamaïque ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩១ កថាខណ្ឌ១៣.៦។

[21] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tadic* សំណុំរឿងលេខ IT-94-I-A សាលដីកា ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ ("សាលដីកាក្នុងរឿងក្តី *Tadic*") កថាខណ្ឌ៤៤។

[22] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីសង្កេតទូទៅ លេខ៣២ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ៣២ និង ៣៣។

១៨. អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បាន សន្និដ្ឋាន "ដូចគ្នានឹងការសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្សដែរថា "រយៈពេលចាំបាច់" សម្រាប់ត្រៀមការពារខ្លួន មិនអាចត្រូវបានវាយតម្លៃក្នុងសភាពអរូបីឡើយ ហើយ រយៈពេលនោះអាស្រ័យទៅលើកាលៈទេសៈជាក់ស្តែង។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក៏ យល់ឃើញដូចគ្នាចំពោះករណី"ភាពងាយស្រួលចាំបាច់"ដែរ។ អង្គជំនុំជម្រះសាលា ឧទ្ធរណ៍បានបន្ថែមទៀតថា "នៅពេលដែលភាគីណាមួយស្នើសុំទៅអង្គជំនុំជម្រះសាលា ដំបូង ដើម្បីឲ្យអង្គជំនុំជម្រះ សាលាដំបូងជួយខ្លួនក្នុងការបង្ហាញនូវអំណះអំណាងរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងត្រូវតែចាត់វាល់វិធានការណ៍គ្រប់បែបយ៉ាងដែលខ្លួនមានភារៈ ត្រូវផ្តល់"។[23]

១៩. ជាក់ស្តែង សេចក្តីជូនដំណឹងកាលពីពេលកន្លងទៅថ្មីៗនេះអំពីភ័ស្តុតាងដាក់បន្ទុកស្តាពរនានាប្រឆាំងទៅនឹងជនជាប់ចោទ ក៏ដូចជាអលទ្ធភាពពិតប្រាកដ ក្នុងដំណាក់កាលនេះ ក្នុង ការកំណត់អំពីភ័ស្តុតាងនានាដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការពារខ្លួន មិន បានផ្តល់ដល់លោក ខៀវ សំផន នូវពេលវេលា ព្រមទាំងភាពងាយស្រួលចាំបាច់នានា សម្រាប់ត្រៀមការពារខ្លួនលោកឡើយ ហើយជាពិសេស ក្នុងការប្រមូលផ្តុំ និងដាក់ ឯកសារនានាពាក់ព័ន្ធទៅនឹងភ័ស្តុតាងរបស់គាត់ ដែលមានប្រភពមកពីគ្រប់ទិសទីក្នុងពិភព លោក ទៅតាមកាលកំណត់នោះ។[24]

២០. មេធាវីការពារបានបរិហារអំពីភាពគ្មានតម្លាភាពនៃកិច្ចស៊ើបសួរ ដែលមានលក្ខណៈជា

---

[23] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា រឿងក្តី *Nahimana និងអ្នកផ្សេងទៀត តទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-99-52-A សាលដីកា ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ២២០ និងកំណត់សម្គាល់ ជើងទំព័រ៥៣២ និង ៥៣៣។

[24] វាជាការសំខាន់ក្នុងការរំឭកថា រឿងក្តីនេះ មានជនជាប់ចោទ ៥នាក់ ដែលការពារខ្លួនថាមិនមែនជាពិរុទ្ធជន និងមានដើមបណ្តឹងរដ្ឋប្បវេណី ២១២៣នាក់។ **កាលៈទេសៈទាំងនេះ មិនអាចប្រៀបធៀបជាមួយនឹងកាលៈទេសៈ នៃរឿងក្តីដែលបានជំនុំជម្រះពីមុនដោយ អ.វ.ត.ក** នោះទេ ដែលនៅក្នុងរឿងក្តីនោះ មានជនជាប់ចោទតែម្នាក់ ហើយជន ជាប់ចោទនោះបានសារភាពពីពិរុទ្ធភាព - និងបានលះបង់ចោលសច្ចធារណ៍និរទោស - មានដើមបណ្តឹងរដ្ឋប្បវេណី ៩០នាក់ (សំណុំរឿង ០០១)។

ការដាក់បន្ទុកសុតសាទ្ធ។[25] ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជម្រះ ដែលបានចូលជាស្ថាពរ ដែលបានតាក់តែងឡើងនៅក្នុងលក្ខខណ្ឌទាំងនេះ គឺជាឯកសារដែលមាន៤៣៥ ទំព័រ [26] ដែលចំនួនទំព័រទាំងនេះត្រូវបានពិនិត្យ និងជំទាស់ដោយលោក ខៀវ សំផន។ ប្រសិនណាជាថេរៈវេលាដែលបានកំណត់ចំពោះសហព្រះរាជអាជ្ញា ក្នុងការដាក់បញ្ជីឈ្មោះសាក្សីរបស់ខ្លួនពុំមានចោទជាបញ្ហា ដោយសារដីកាដំណោះស្រាយមានលក្ខណៈដូចគ្នាបន្តិចបន្តួចទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួន ដូច្នេះ ក្នុងដំណាក់កាលនេះ លោក ខៀវ សំផន មិនអាចដឹងបានថា តើខ្លួនលោកត្រូវរៀបចំការពារខ្លួនលោកដោយផ្អែកលើមូលដ្ឋានណាមួយនោះឡើយ ដោយយោងទៅលើចំនួនសាក្សីដ៏ច្រើនសន្ធឹកសន្ធាប់របស់ព្រះរាជអាជ្ញា ព្រមទាំងជម្រើសដែលព្រះរាជអាជ្ញាត្រូវប្រកាន់យកក្នុងការជ្រើសរើសអ្នកជំនាញរបស់ខ្លួន។

២១. ក្នុងអំឡុងពេលនៃការស៊ើបអង្កេតបឋម ដែលបង្កើតឱ្យមានជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហព្រះរាជអាជ្ញាមានឱកាស ពេលវេលា និងមធ្យោបាយក្នុងការជួប និងសម្ភាសសាក្សី ដោយហេតុថាសហព្រះរាជអាជ្ញាមានធនធានអ្នកស៊ើបអង្កេតជាច្រើននាក់។ ដោយឡែក សហព្រះរាជអាជ្ញាក៏បានទទួលផងដែរនូវសិទ្ធិក្នុងការផ្ទេរឯកសារភ័ស្តុតាងនានានៃសំណុំរឿង០០១ទៅកាន់សំណុំរឿង០០២ ដែលទង្វើនេះមានលក្ខណៈអយុត្តិធម៌ជាខ្លាំង ព្រោះថាក្រុមមេធាវីការពារពុំមានវត្តមាននៅក្នុង សំណុំរឿង០០១ នោះ។ ផ្ទុយទៅវិញ មេធាវីការពារពុំមានអំណាចក្នុងប្រមូលផ្តុំឯកសារភ័ស្តុតាងដើម្បីធ្វើការការពារក្តីរបស់ខ្លួនបានឡើយ ពីព្រោះពួកគេត្រូវបានហាមឃាត់ដាច់ខាតមិនឱ្យធ្វើដូច្នោះ។[27] ដូច្នេះ

---

[25] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារតុលាការ D427/4/3, កថាខណ្ឌ៧៤ ដល់ ១១៣។ **អង្គបុរេជំនុំជម្រះ បានទទួលស្គាល់ថា សហចៅក្រមស៊ើបអង្កេត មិនបានបកស្រាយឱ្យមានត្រឹមត្រូវនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការស្វែងរកភ័ស្តុតាងដោះបន្ទុក៖** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ៣៧ និង ៣៨។

[26] ដោយមិនរាប់បញ្ចូលកំណត់សម្គាល់ជើងទំព័រ ៣៥៥ទំព័រ ដែលនៅតែមិនទាន់ត្រូវបានបកប្រែជាភាសាបារាំង។

[27] សូមមើលផងដែរ៖ សំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះលើសំណុំរឿងលេខ ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើសុំ និងសំណុំសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ដើម្បីដាក់ឯកសារភ័ស្តុតាង សម្រាប់រៀបចំសវនាការ ឯកសារ E9/3 កថាខណ្ឌ២៦ និង ២៧។

មេធាវីការពារពុំមានពេលវេលា និងភាពងាយស្រួល ដូចគ្នាទៅនឹងសហព្រះរាជអាជ្ញាឡើយ ក្នុងការត្រៀមរៀបចំឯកសារភ័ស្តុតាងរបស់ខ្លួននោះ។

២២. ស្ថានភាពនេះផ្ទុយគ្នាទៅនឹងគោលការណ៍សមភាពនៃមធ្យោបាយការពារក្តី ដែលចរិតលក្ខណៈជាសារវន្តនៃគោលការណ៍នេះត្រូវបានទទួលស្គាល់ដោយវិធានផ្ទៃក្នុង ក៏ដូចជាអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក.។[28] ផ្អែកលើយុត្តិសាស្ត្រនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប សមភាពនៃមធ្យោបាយការពារក្តីតម្រូវឱ្យផ្តល់ដល់ភាគីនីមួយៗ នូវលទ្ធភាពសមស្របក្នុងការបង្ហាញនូវអំណះអំណាងរបស់ខ្លួនរួមទាំងភ័ស្តុតាងនានា នៅក្នុងលក្ខខណ្ឌដែលពុំដាក់ពួកគេនៅក្នុងស្ថានភាពចាញ់ប្រៀបដាច់ បើធៀបទៅនឹងភាគីម្ខាងទៀត។[29]

២៣. ជាក់ស្តែង មេធាវីការពារពុំមែនត្រឹមតែគ្មានឱកាសក្នុងការប្រមូលនូវភ័ស្តុតាងផ្ទាល់របស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែមេធាវីការពារខ្វះខាតនូវព័ត៌មានស្តីអំពីភ័ស្តុតាងដែលបង្ហាញឡើងដោយភាគីដទៃទៀត។

២៤. នៅក្នុងរឿងក្តី *Öcalan* អង្គជំនុំជម្រះជាន់ខ្ពស់នៃតុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា រយៈពេលខ្លីនៅចន្លោះការជូនដំណឹងអំពីការចោទប្រកាន់ និងសវនាការ ក៏ដូចជាការលំបាករបស់មេធាវីក្នុងការទទួលបានឯកសារនៃសំណុំរឿង នៅក្នុងដំណាក់កាលដែលមានការយឺតយ៉ាវ ពុំអាចឱ្យជនជាប់ចោទទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ឡើយ។ អង្គជំនុំជម្រះជាន់ខ្ពស់នៃតុលាការសិទ្ធិមនុស្សអឺរ៉ុបបានប្រកាសថា៖"គោលការណ៍សមភាពនៃមធ្យោបាយការពារក្តីជាធាតុផ្សំនៃសញ្ញាណដ៏ទូលំទូលាយ នៃការកាត់សេចក្តីដោយយុត្តិធម៌ ដោយក្រសោបទាំងសិទ្ធិជាសារវន្តដែលមានលក្ខណៈចំពោះមុខនៃនីតិវិធីព្រហ្មទណ្ឌផងដែរ។ សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីព្រហ្មទណ្ឌដោយមានលក្ខណៈចំពោះមុខផ្តល់ដល់អយ្យការ ក៏ដូចជាមេធាវីការពារ នូវលទ្ធភាពជ្រួតជ្រាបពីកំណត់សម្គាល់ ឬភ័ស្តុ

---

[28] ឧទាហរណ៍ សូមមើល៖ *សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំដាក់អំណះអំណាងឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ E90 កថាខណ្ឌ០៥។

[29] តុលាការសិទ្ធិមនុស្សអឺរ៉ុប ថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៣ សំណុំរឿងលេខ ១៤៤៤៨/៨៨ រឿងក្តី Dombo Beheer BV តទល់នឹងប្រទេសហូឡង់ កថាខណ្ឌ៣៣។

00642993



តាងនានាដែលបានដាក់ដោយភាគីម្ខាងទៀត ក៏ដូចជាលទ្ធភាពក្នុងការពិភាក្សាលើឯកសារទាំងនោះផងដែរ។ ច្បាប់ជាតិអាចធ្វើការបំពេញសេចក្តីទាមទារនេះតាមវិធីច្រើនយ៉ាង ប៉ុន្តែវិធីសាស្ត្រដែលអនុម័តដោយច្បាប់ជាតិត្រូវធានាថា មេធាវីការពារមានលទ្ធភាពពិតប្រាកដក្នុងការបញ្ចេញមតិរបស់ខ្លួន លើការចោទប្រកាន់នានារបស់អយ្យការ"។[30]

២៥. ជាក់ស្តែង ថេរៈវេលារវាងការជូនដំណឹងអំពីភស្តុតាងដាក់បន្ទុកស្តាពរ ការដាក់បញ្ជីឈ្មោះសាក្សីទាំង ២៩៤ នាក់ និងឈ្មោះអ្នកជំនាញរបស់សហព្រះរាជអាជ្ញា ព្រមទាំងថេរវេលាសម្រាប់ការដាក់នូវឯកសារពាក់ព័ន្ធទៅនឹងភស្តុតាងរបស់សហព្រះរាជអាជ្ញា មានគម្លាតជិតគ្នាពេក ជាហេតុធ្វើឲ្យមេធាវីការពារមិនអាចត្រៀមរៀបចំការពារខ្លួនបានតាមសម្រួល និងដោយយុត្តិធម៌ឡើយ។

២៦. ជាក់ស្តែង នៅក្នុងខណៈដែលអយ្យការត្រូវបង្ហាញនូវភស្តុតាងអំពីពិរុទ្ធភាពរបស់លោក ខៀវ សំផន ខ្លឹមសារនៃឯកសារដែលពាក់ព័ន្ធនឹងភស្តុតាងរបស់អយ្យការពឹងផ្អែកលើការពិនិត្យលើភស្តុតាងដាក់បន្ទុកដែលកំណត់យក លើបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញា លើបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី លើឯកសារសង្ខេបដែលអាចឲ្យគេយល់បានអំពីប្រភេទ និងអត្ថន័យនៃសក្ខីកម្មដែលបានស្នើឡើង ព្រមទាំងភស្តុតាងដាក់បន្ទុកទាំងឡាយដែលបង្ហាញឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

២៧. គេអាចនិយាយបានម្យ៉ាងទៀតថា ដើម្បីដឹងថាតើភស្តុតាងណាខ្លះដែលបានដាក់ទៅអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវតែអាចត្រួតពិនិត្យមើលនូវរាល់ឯកសារភស្តុតាងដែលបានបង្ហាញឡើងដោយភាគីដទៃទៀតទាំងអស់ ដើម្បីអាចធ្វើការពិភាក្សា ធ្វើការវាយតម្លៃ ព្រមទាំងដាក់ឯកសារទាំងអស់នោះទៅក្នុងបរិបទនៃការកាត់សេចក្តី និងការការពារខ្លួននៅចំពោះមុខតុលាការ។

២៨. យោងទៅលើភាពធ្ងន់ធ្ងរនៃអង្គហេតុ ដែលបានចោទប្រកាន់ទៅលើលោក ខៀវ សំផន ព្រមទាំងទៅលើភាពស្មុគស្មាញនៃសំណុំរឿង០០២ ព្រមទាំងទៅលើថេរៈវេលាកំណត់ លោក ខៀវ សំផន ពុំទទួលបាននូវពេលវេលា ព្រមទាំងភាពងាយស្រួលចាំបាច់សម្រាប់

[30] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Öcalan* ***តទល់នឹង*** ប្រទេស *Turquie* ពាក្យស្នើសុំលេខ ៤៦២២១/៩៩ សាលដីការបស់អង្គជំនុំជម្រះជាន់ខ្ពស់ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ១៤៦។

ត្រៀមរៀបចំការពារខ្លួននៅចំពោះមុខតុលាការឡើយ។ ស្ថានភាពនេះបង្កឱ្យមានជាការសោកស្តាយខ្លាំងថែមទៀត ដោយហេតុថាវាបានពាក់ព័ន្ធទៅនឹងដំណាក់កាលសំខាន់មួយនៃការជំនុំជម្រះ ដែលមានមានគោលដៅស្វែងរកការពិត។

២៩. យោងទៅលើវិធានផ្ទៃក្នុង សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកទៅលើភ័ស្តុតាងតែមួយគត់ដែលបានបង្ហាញឡើងនៅក្នុងអង្គសវនាការ ដោយភាគី ឬដោយអង្គជំនុំជម្រះផ្ទាល់តែម្តង។[31] កាលពីពេលមុន អង្គជំនុំជម្រះបានសម្រេចលើករណីនៃការបង្ហាញខ្លួនរបស់សាក្សីដែលមានឈ្មោះនៅក្នុងបញ្ជីរបស់ភាគី។[32] ដូចនេះ ការដាក់ឯកសារពាក់ព័ន្ធទៅនឹងភ័ស្តុតាងមានសារៈសំខាន់ណាស់ចំពោះលោក ខៀវ សំផន។ ដោយឡែកនៅក្នុងដំណាក់កាលនេះ ប្រសិនណាជាលោក ខៀវ សំផន មិនអាចដឹងថាតើខ្លួនលោកត្រូវផ្អែកលើឯកសារភ័ស្តុតាងមួយណា ដោយហេតុពុំបានទទួលព័ត៌មានពីដំបូងស្តីអំពីសក្ខីកម្មនានារបស់អយ្យការ និងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះ លោក ខៀវ សំផន មិនអាចបំពេញនូវកាតព្វកិច្ចដែលមិនអាចទៅរួច ពោលគឺការបង្ហាញនូវឯកសារភ័ស្តុតាងរបស់ខ្លួនក្នុងថេរៈវេលាស្ទួចស្តើង។

៣០. ជាក់ស្តែង វាទំនងជាមានការលំបាកខ្លាំងណាស់ក្នុងការពឹងផ្អែកទៅលើបញ្ជីឈ្មោះសាក្សីដែលបានបង្ហាញនៅពេលដែលបញ្ជីឈ្មោះនោះត្រូវបានដាក់ ទោះបីជាមុនពេលបើកសវនាការបឋម ឬនៅក្នុងអំឡុងពេលនៃការកាត់សេចក្តីក៏ដោយ។ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងបានកំណត់នូវលក្ខណវិនិច្ឆ័យតឹងរ៉ឹងពាក់ព័ន្ធនឹងភាពដែលអាចទទួលយកបាននៃភ័ស្តុតាងថ្មីៗមុនពេលបើកសវនាការបឋម រហូតដល់ពេលដែលត្រូវពិនិត្យមើលថាតើសំណើសុំពុំមានបង្កប់នូវកលល្បិចដោយចេតនា ដែលមានគោលដៅបង្វែងដំណាក់កាលនៃកិច្ចស៊ើបសួរនោះ។[33]

---

[31] វិធាន ៨៧ ២) និង ៣) នៃវិធានផ្ទៃក្នុង។

[32] វិធាន ៨០ *ស្ទួន* ២) នៃវិធានផ្ទៃក្នុង។

[33] រឿងក្តី "ឌុច" សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃភ័ស្តុតាងថ្មី និងសេចក្តីណែនាំដល់ភាគីទាំងអស់ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ ឯកសារ E5/10/2 កថាខណ្ឌ០៦ និង ១២។

៣១. នៅក្នុងដំណាក់កាលនៃការជំនុំជម្រះ វិធាន ៨៧ ៤) នៃវិធានផ្ទៃក្នុងបានអនុញ្ញាតឲ្យភាគីធ្វើការស្នើសុំអង្គជំនុំជម្រះសាលាដំបូងធ្វើការពិនិត្យមើលសក្ខីកម្មថ្មីៗ "ដែលអង្គជំនុំជម្រះយល់ឃើញថាចាំបាច់ដល់ការបង្ហាញការពិត"។ ក្រៅអំពីកាតព្វកិច្ចក្នុងការផ្តល់អំណះអំណាងដល់សំណើសុំនេះ ដោយផ្អែកលើលក្ខណវិនិច្ឆ័យទាំងប្រាំនៃភាពដែលអាចទទួលយកបាន ដូចបានបញ្ជាក់នៅក្នុងកថាខណ្ឌមុននេះ[34] ភាគីម្ចាស់សំណើត្រូវធ្វើការបញ្ចុះបញ្ចូលអង្គជំនុំជម្រះថា សក្ខីកម្មដែលបានស្នើពុំទាន់មាននៅឡើយទេ នៅមុនពេលបើកសវនាការ។ យោងទៅលើអ្វីដែលបានបកស្រាយ ពាក់ព័ន្ធទៅនឹងភាពដែលអាចទទួលយកបាននៃភ័ស្តុតាងថ្មីៗមុនពេលការបើកសវនាការបឋម វាច្បាស់ណាស់ថាលក្ខណវិនិច្ឆ័យទាំងនេះ ក៏ត្រូវបានបកស្រាយក្នុងលក្ខណៈតឹងរ៉ឹងដែរ។

## ខ. សិទ្ធិទទួលបានការជំនុំជម្រះនៅក្នុងលក្ខខណ្ឌល្អប្រសើរ និងដោយគ្មានការយឺតយ៉ាវហួសហេតុ

៣២. ដូចគ្នាទៅនឹងកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយដែរ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ចែងថា ជនជាប់ចោទទាំងឡាយមានសិទ្ធិទទួលបានការជំនុំជម្រះដោយមិនយឺតយ៉ាវហួសហេតុ។[35] យោងលើវិធាន ២១ ៤) នៃវិធានផ្ទៃក្នុង "ការចោទប្រកាន់ដែលធ្វើឡើងនៅចំពោះមុខអ.វ.ត.ក. ត្រូវតែបានជំនុំជម្រះក្នុងថេរៈវេលាមួយសមស្រប"។

៣៣. ថេរៈវេលាបន្ថែមដែលបានស្នើសុំដោយលោក ខៀវ សំផន ពុំបានបង្កើតអនុភាពជាការពន្យារការចាប់ផ្តើមសវនាការនោះទេ ហើយផ្ទុយទៅវិញ ថេរៈវេលានៃការជំនុំជម្រះក៏ពុំមានលក្ខណៈគ្រប់គ្រាន់ផងដែរ។ ការដែលជនជាប់ចោទទទួលបាននូវពេលវេលា ព្រម

---

[34] វិធាន ៨៧ ៣) នៃវិធានផ្ទៃក្នុង៖ "អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖ ក-មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ គ-មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង ឃ-ច្បាប់មិនអនុញ្ញាត ឬ ង-មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍"។

[35] មាត្រា ១៤ ៣) គ) នៃ កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៣៥ ថ្មី គ) នៃច្បាប់បង្កើត អ.វ.ត.ក។

ទាំងភាពងាយស្រួលនានាចាំបាច់ដល់ការត្រៀមរៀបចំបញ្ជីឈ្មោះសាក្សីរបស់ខ្លួន នឹងកាត់បន្ថយនូវហានិភ័យនៃភាពយឺតយ៉ាវនៅក្នុងអំឡុងនៃការប្រព្រឹត្តិទៅនៃអង្គសវនាការ៖ សំណើសុំព័ត៌មានបន្ថែម បណ្តឹងឧទ្ធរណ៍នានាប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ការព្យួរ...។ ម្យ៉ាងទៀត ចំណុចនេះបានបង្កើតឲ្យមានជាភាពស៊ីសង្វាក់គ្នានៅក្នុងលំដាប់លំដោយនៃការបង្ហាញភ័ស្តុតាងក្នុងអំឡុងពេលនៃការជំនុំជម្រះ។

៣៤. ការពន្យារថេរៈវេលាកំណត់សម្រាប់ការដាក់នូវបញ្ជីឈ្មោះសាក្សីបន្ថែម មិនត្រឹមតែធានាដល់ការគោរពសិទ្ធិជាសារវន្តរបស់លោក ខៀវ សំផន ប៉ុណ្ណោះទេ ប៉ុន្តែជាការធានាដល់ភាពឆាប់រហ័ស និងប្រសិទ្ធិភាពនៃនីតិវិធី ដើម្បី**ការពិត និងយុត្តិធម៌**។

## ហេតុដូច្នេះ

៣៥. លោក ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **កត់សម្គាល់ថា** ការអនុវត្តវិធាន៨០ នៃវិធានផ្ទៃក្នុង បានរំលោភលើគោលការណ៍ "សន្មតថា គ្មានទោស" របស់ លោក ខៀវ សំផន ដែលតាមរយៈគោលការណ៍នេះបន្ទុកនៃភស្តុតាងធ្លាក់ទៅលើអយ្យការ និងរំលោភសិទ្ធិរបស់លោក ខៀវ សំផន ដែលត្រូវតែស្មើភាពគ្នាទៅនឹងការងារ ក៏ដូចជាភារកិច្ចរបស់សហព្រះរាជអាជ្ញា ក្នុងការទទួលបាននូវពេលវេលា ព្រមទាំងភាពងាយស្រួលនានាចាំបាច់ដល់ការត្រៀមការពារខ្លួនលោក ក៏ដូចជាសិទ្ធិទទួលបានការកាត់សេចក្តីដោយគ្មានភាពយឺតយ៉ាវហួសហេតុផងដែរ។

- **អនុញ្ញាត**ឲ្យលោក ខៀវ សំផន ដាក់ឯកសារនានាពាក់ព័ន្ធទៅនឹងភ័ស្តុតាងរបស់លោក បន្ទាប់ពីមានការបង្ហាញនូវមធ្យោបាយភ័ស្តុតាងរបស់សហព្រះរាជអាជ្ញា និងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយពុំបានបង្កើតឲ្យមានជាព្យសនកម្មដល់សិទ្ធិរបស់គាត់ក្នុងការដាក់នូវភ័ស្តុតាងថ្មីៗ នៅក្នុងអំឡុងពេលជំនុំជម្រះ។

- **សម្រេចថា** ថេរៈវេលាកំណត់សម្រាប់ការដាក់ឯកសារពាក់ព័ន្ធនឹងឯកសារភ័ស្តុតាង នឹងចាប់ផ្តើមគិតចាប់ពីពេលដែលមានការជូនដំណឹងជាភាសាបារាំង អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងសំណើសុំនេះ។

**រក្សាសិទ្ធិគ្រប់យ៉ាង**

**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី ស សូវាន | ភ្នំពេញ | |
| P. | មេធាវី Jacques VERGÈS | ប៉ារីស | |
| P. | មេធាវី Philippe GRECIANO | ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |